**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិ**
រៀបចំបុណ្យជាតិ អន្តរជាតិ
លេខ: ១៣ /.................គជបអ
/២០១៧

# ផែនការណែនាំ
## ស្តីពីការរៀបចំខួបអនុស្សាវរីយ៍លើកទី ៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០១៧

---

**យោង:** ព្រះរាជក្រឹត្យលេខ នស/រកត ០៨០៥/៣៥៤ ចុះថ្ងៃទី៥ ខែសីហា ឆ្នាំ២០០៥ ស្តីពីការកែសម្រួល **គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ** ទៅជា **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

-អនុក្រឹត្យលេខ២២៣អនក្រ-បក ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំឆ្នាំ២០១៧

-សារាចរណែនាំ សម្រាប់អនុវត្តជាអចិន្ត្រៃយ៍ លេខ០៩សរណន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំចាត់តាំងព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យប្រពៃណីជាតិ ប្រពៃណីសាសនា បុណ្យជាតិ-បុណ្យអន្តរជាតិ

-លិខិតលេខ ៦៣១សជណ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីសំណើសុំគោលការណ៍អនុញ្ញាត និងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី អំពីការរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងការរៀបចំខួបអនុស្សាវរីយ៍លើកទី៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០១៧

ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៦៤ នៃទិវាបុណ្យឯករាជ្យជាតិ និងទិវាកំណើតនៃកងយោធពល-ខេមរភូមិន្ទ នឹងត្រូវប្រព្រឹត្តទៅនៅថ្ងៃទី៩-១០និងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧ ដើម្បីសម្តែងនូវទឹកចិត្តសោមនស្សរីករាយអបអរសាទរយ៉ាងក្លៀវក្លាបំផុត ចំពោះទិវាជាប្រវត្តិសាស្ត្រ ដែលកម្លាំងមហាសាមគ្គីជាតិទាំងមូលដណ្តើមបានទាំងស្រុងមកវិញពីអាណានិគមនិយមបារាំងនាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នូវឯករាជ្យជាតិដ៏ពេញបរិបូណ៌ ក្រោមព្រះរាជបុជនីយកិច្ចដ៏ថ្លៃថ្លាឧត្តុង្គឧត្តម នៃ **ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** ។

ដើម្បីចាត់តាំងរៀបចំពិធីបុណ្យនេះ ឱ្យបានមហោឡារិក ស័ក្តិសមទៅនឹងអត្ថន័យដ៏ជ្រាលជ្រៅ ដូចបានបញ្ជាក់ខាងលើ **គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** សូមដាក់ចេញនូវផែនការណែនាំដូចខាងក្រោម ៖

*<u>នៅរាជធានីភ្នំពេញ</u> ត្រូវចាត់តាំងរៀបចំខួបអនុស្សាវរីយ៍លើកទី៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ក្នុងរូបភាពមួយសមស្របទៅនឹងកិត្តិយសប្រទេសជាតិ ដោយមានចាត់តាំងមីទ្ទិញមហាជនមួយ នៅបរិវេណវិមានឯករាជ្យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដោយមានសម្តេចព្រះមហាសង្ឃរាជ សម្តេចព្រះសង្ឃនាយក សម្តេចព្រះសង្ឃនាយករង មន្ត្រីសង្ឃជាន់ខ្ពស់ មានថ្នាក់ដឹកនាំកំពូលជាតិ មន្ត្រីរាជការ ស៊ីវិល យោធា កងរាជអាវុធហត្ថ នគរបាល លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ប្រជារាស្ត្រ និងភ្ញៀវអន្តរជាតិ ចូលរួមឲ្យបានច្រើនកុះករ និងមានចាត់តាំងពិធីប្រទានភ្លើងជ័យ ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ ព្រមទាំងមានបង្ហោះប៉េងប៉ោងលែងព្រាបជានិមិត្តរូបនៃការសុំសុខសន្តិភាពនៅថ្ងៃទី៩ និងពិធីពន្លត់ភ្លើងជ័យ នៅពេលល្ងាចថ្ងៃទី១១ ខែវិច្ឆិកា ដោយមានរូបភាពចាត់តាំងកម្លាំងមហាជនចូលរួម ដូចថ្ងៃប្រទានភ្លើងជ័យដែរ ហើយនៅរាត្រីថ្ងៃទី៩ និងថ្ងៃទី១១ នឹងមានការអុជកាំជ្រួចអបអរសាទរក្នុងពិធីនេះផង ។

*<u>គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងសាលារាជធានីភ្នំពេញ</u> ត្រូវចាត់តាំងគណៈប្រតិភូដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៧។

-ថ្នាក់ដឹកនាំ មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ចូលរួមប្រារព្ធពិធីបុណ្យឯករាជ្យជាតិ នៅវិមានឯករាជ្យ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។

-តុបតែងលម្អភ្លើងពណ៌ ចងបដាពាក្យស្លោក ទង់ជាតិ ទង់ក្ដែប តាមអង្គភាពរបស់ខ្លួន ដើម្បីអបអរពិធីបុណ្យដ៏ថ្លៃថ្លាឧត្តុង្គឧត្តមនេះ។

*<u>គ្រប់ខេត្ត</u> ត្រូវចាត់តាំងពិធីមីទ្ទិញមហាជន និងពិធីគោរពវិញ្ញាណក្ខន្ធ នៅតាមទីកន្លែងដ៏សមគួរដែលខេត្តនីមួយៗបានជ្រើសរើស។ ណែនាំដល់អង្គភាពក្រោមឱវាទ រោងចក្រ សហគ្រាស សាលារៀន និងលំនៅដ្ឋានប្រជារាស្ត្រ ឲ្យ ចងទង់ជាតិ ទង់ក្ដែប ចងបដាពាក្យស្លោក អបអរសាទរពិធីបុណ្យខាងលើ។

* <u>ក្រសួងព័ត៌មាន</u> ចាត់តាំងឲ្យមានកម្មវិធីផ្សព្វផ្សាយខ្លឹមសារ និងអត្ថន័យ នៃទិវាបុណ្យឯករាជ្យជាតិឲ្យបានទូលំទូលាយ តាមវិទ្យុ ទូរទស្សន៍ជាតិ និងឯកជន ស្ដីពីព្រះរាជសកម្មភាពនៃ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ"** កាលព្រះអង្គមានព្រះជន្មគង់នៅ និងការរីកចម្រើនលើគ្រប់វិស័យ ក្រោមការដឹកនាំរបស់ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងមានកម្មវិធីផ្សាយផ្ទាល់នូវពិធី ប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា។

*<u>ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ</u> ត្រូវធ្វើការណែនាំដល់គ្រប់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈ រាជធានី ខេត្ត ចាត់តាំងក្រុមសិល្បៈ និងក្រុមតន្ត្រីសម័យ បុរាណ សម្តែង និងប្រគំជូនប្រជារាស្ត្រទស្សនាកម្សាន្ត តាមទីសាធារណៈដែលបានកំណត់។

*<u>ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ</u> ត្រូវត្រៀមលក្ខណៈដោះស្រាយសម្ភារ និងថវិកាសម្រាប់បម្រើការរៀបចំពិធីបុណ្យខាងលើឱ្យបានសមស្រប និងទាន់ពេលវេលា ។

*<u>ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ</u> ត្រូវចាត់តាំងកម្លាំងការពាររក្សាសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់សង្គម ចរាចរណ៍ តាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព សេចក្តីសុខក្សេមក្សាន្ត និងសេចក្តីសប្បាយរីករាយជូនប្រជារាស្ត្រយើង ។

*<u>ក្រសួងការពារជាតិ</u> ត្រូវរៀបចំកម្មវិធីលម្អិត ដោយឡែកប្រារព្ធខួបលើកទី៦៤ នៃទិវាកំណើតកងយោធពលខេមរភូមិន្ទ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅទីតាំងដ៏សមស្របណាមួយដោយធានាបានរូបភាពចាត់តាំង និងខ្លឹមសារ។ ចាត់តាំងការអុជកាំជ្រួចរយៈពេល២ថ្ងៃ គឺថ្ងៃទី៩ និងថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង១៩យប់ នៅមុខព្រះបរមរាជវាំង។

*<u>គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ</u> ផ្តល់ការណែនាំដល់សាលារាជធានីភ្នំពេញ ក្នុងការរៀបរយមហាជននៅបរិវេណវិមានឯករាជ្យ និងតាមមហាវិថីសម្តេចសុធារស និងមហាវិថីព្រះសុរាម្រិត ក្នុងពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុត **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត។

-រៀបចំកម្មវិធីជូនគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន និងរាជធានីភ្នំពេញ អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ នៅវិមានឯករាជ្យ និងថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា "ព្រះបរមរតនកោដ្ឋ"** នាមណ្ឌបសួនច្បារខាងកើតវិមានឯករាជ្យ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០១៧។

**គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ** សង្ឃឹមថា ថ្នាក់ដឹកនាំគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត យកចិត្តទុកដាក់អនុវត្តនូវផែនការណែនាំនេះ ឱ្យបានសម្រេចលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរ នៃរាជរដ្ឋាភិបាល ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧

**គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ**

**ប្រធាន**

**សម្តេចចៅហ្វាវាំង វរសេនីយ៍ឯក អធិបតីស្រីវង្ស គង់ សំអុល**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រីប្រចាំការ

"ដើម្បីជូនជ្រាប"

- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន រាជធានី និងគ្រប់ខេត្ត

"ដើម្បីសហការអនុវត្ត"

- ឯកសារ-កាលប្បវត្តិ

# ពាក្យស្លោកសម្រាប់ប្រើ

## ក្នុងការរៀបចំខួបអនុស្សាវរីយ៍លើកទី ៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និងទិវាកំណើតនៃកងយោធពលខេមរភូមិន្ទ ឆ្នាំ២០១៧

១- សូមថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតា ឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" សូមបានយាងទៅសោយព្រះបរមសុខក្នុងសុគតិភព

២- សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមមានព្រះរាជសុខភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ

៣- សូមថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សូមមានព្រះរាជសុខភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ

៤- ជយោ! ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

៥- អបអរសាទរខួបអនុស្សាវរីយ៍លើកទី ៦៤ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា (៩.១១.១៩៥៣ - ៩.១១.២០១៧)

៦- ចងចាំជានិច្ចនូវព្រះរាជបុជនីយកិច្ចតាមទារឯករាជ្យជាតិដ៏ឧត្តុង្គឧត្តម នៃព្រះករុណាព្រះបាទសម្តេច **ព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"

៧- ជយោ! លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា

៨- ជយោ! សន្តិភាព និងការបង្រួបបង្រួមជាតិ

៩- ជយោ! ព្រះរាជាណាចក្រកម្ពុជា

១០- ជាតិ សាសនា ព្រះមហាក្សត្រ

១១- ជយោ! សន្តិភាព និងការអភិវឌ្ឍ

១២- អបអរសាទរ ខួបអនុស្សាវរីយ៍លើកទី ៦៤ នៃទិវាកំណើតកងយោធពលខេមរភូមិន្ទ (៩.១១.១៩៥៣ - ៩.១១.២០១៧)

១៣- ប្តេជ្ញាការពារឯករាជ្យជាតិ បូរណភាពទឹកដី ឲ្យបានគង់វង្ស ជានិច្ចនិរន្តរ៍